# វិធីសាស្ត្របង្រៀនកុមារតូច

សិក្ខាសាលា៖ ឧត្តម្មានុវត្តន៍វិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យ បឋម និងមធ្យមសិក្សា

ថ្ងៃទី២៩ ដល់ ៣០ ខែមិថុនា ឆ្នាំ២០២៤

សាលពហុបំណង CKCC, RUPP



# ខ្លឹមសារ

- បរិបទទូទៅ
- ក្របខណ្ឌកម្មវិធីសិក្សា K-12
- កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា
- វិធីសាស្រ្តបង្រៀននៅកម្រិតមត្តេយ្យសិក្សា
- សន្និដ្ឋាន



# បរិបទទូទៅ



វិធីសាស្រ្តបង្រៀនកុមារតូច គឺជារបៀប មធ្យោបាយ ឬជាល្បិចសម្រាប់យកមកប្រើក្រោមការដឹកនាំរបស់គ្រូមត្តេយ្យសិក្សានាំកុមារឱ្យអនុវត្តសកម្មភាពដែលបានគ្រោងទុកដោយសិស្ស និងគ្រូក្នុងការសម្រេចឱ្យបាននូវចំណេះដឹង ចំណេះធ្វើ ឥរិយាបថ និងការចេះរស់នៅជាមួយគ្នា ព្រមទាំងពង្រីកសតិបញ្ញារបស់កុមារស្របតាមកម្មវិធីសិក្សាលម្អិតនៅកម្រិតមត្តេយ្យសិក្សា។ (វីដេអូ៖ សកម្មភាពរៀននៅកម្រិតមត្តេយ្យ)

# ក្របខណ្ឌកម្មវិធីសិក្សា K-12




- អនុម័តប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡានាឆ្នាំ ២០១៦
- ចក្ខុវិស័យ៖ ជានាអប់រំប្រជាពលរដ្ឋមានលក្ខណៈសម្បត្តិពេញលេញលើការអភិវឌ្ឍន៍វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា មានមនសិកាស្នេហាជាតិ និងមនុស្សជាតិ ដើម្បីអភិវឌ្ឍន៍ជាតិ ធ្វើសមហរណកម្មកម្ពុជាចូលក្នុងតំបន់និងពិភពលោក។
- គោលបំណង៖ បង្កើនអ្នកសិក្សាលើសមត្ថភាពភាសាខ្មែរ និងបរទេស លើបំណិនទាំងបួន (ស្តាប់ និយាយ អាន និងសរសេរ) សមត្ថភាពគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា ទូរគមនាគមន៍ បំណិនសិល្បៈ សុខភាព កីឡា និងសោភណ័ភាព នវានុវត្តន៍ សហគ្រិនភាព និងពលរដ្ឋវិជ្ជា បំណិនស្វ័យសិក្សា ស្រាវជ្រាវត្រិះរិះពិចារណា ប្រាស្រ័យទាក់ទង ដោះស្រាយបញ្ហា សមត្ថភាពវាយតម្លៃ សមត្ថភាពសម្រេចចិត្ត ការយល់ដឹងនិងការបំពេញភាតព្វកិច្ចសិទ្ធិពលរដ្ឋ និងបំណិនសិក្សាពេញមួយជីវិត។

# កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា

- ផ្សព្វផ្សាយប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា នាឆ្នាំ ២០១៨
- គោលបំណង៖
  - ជានាការអប់រំប្រកបដោយបរិយាបន្ន សមធម៌គុណភាព និងលោកកម្ពស់ការសិក្សាពេញមួយជីវិត
  - ជាពិសេសត្រឹមកំណត់ចំណុចដៅឆ្នាំ ២០៣០ ធានា កុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព និងត្រៀមខ្លួនរួចជាស្រេចចូលរៀនថ្នាក់ទី១នៅបឋមសិក្សា
  - គោលបំណងរួមគឺអភិវឌ្ឍន៍ កាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា








# កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា

- គោលដៅរួម៖ រៀនប្រើប្រាស់ញាណ ចិត្តចលភាព ការលេង និងអនុវត្តផ្ទាល់ ការត្រិះរិះពិចារណា និងដោះស្រាយបញ្ហា វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត ភាសាខ្មែរ







# វិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យសិក្សា

- **គោលការគ្រឹះ**
  - ការបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល
  - ការសិក្សាតាមរយៈការលេងនិងសហការ
  - ការផ្ដល់ទំនុកចិត្តដល់កុមារ ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយការ សុវត្ថិភាព និងភាពកក់ក្ដៅ
  - កុមារជាអ្នកកសាងចំណេះដឹងដោយខ្លួនឯង គ្រូជាអ្នកដឹកនាំ
  - ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀនតាមរយៈវិធីសាស្ត្រចម្រុះ
  - ការរៀនតាមរយៈដាក់ស្ដែង និងវិទ្យាសាស្ត្រ

*(កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ឆ្នាំ ២០១៨)*



# វិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យសិក្សា

## វិធីសាស្ត្របង្រៀនជាទូទៅសម្រាប់មត្តេយ្យសិក្សា៖

- **Montessori Method** (ផ្តោតលើសិស្សមជ្ឈមណ្ឌល, អនុញ្ញាតិឱ្យកុមារជាអ្នកដឹកនាំការសិក្សារបស់ខ្លួនផ្ទាល់, គ្រូជាអ្នកសម្របសម្រួល, ថ្នាក់រៀនរៀបចំសម្ភារដែលអាចឱ្យកុមារចាប់អារម្មណ៍ និងមានជម្រើសលេងនិងសិក្សាយ៉ាងសំបូរបែប)
- **Reggio Emilia Approach** (ផ្តោតលើការជឿជាក់ថាកុមារមានសមត្ថភាព ធនធាន និងចង់ដឹងចង់ឃើញ, បរិស្ថានគឺជាគ្រូទី ៣របស់កុមារ, ជំរុញយ៉ាងខ្លាំងដល់ការរៀនសូត្រតាមគម្រោង ដែលកុមារស្វែងរកប្រធានបទយ៉ាងស៊ីជម្រៅសម្រាប់រយៈពេលបន្ត, ឪពុកម្តាយ គ្រូបង្រៀន និងសហគមន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀនសូត្ររបស់កុមារនៅក្នុងវិធីសាស្ត្រនេះ)



# វិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យសិក្សា

## វិធីសាស្ត្របង្រៀនជាទូទៅសម្រាប់មត្តេយ្យសិក្សា៖

- **Waldorf Steiner Method** (ផ្តោតលើសារៈសំខាន់នៃការរៀនបែបស្រមើស្រមៃ, គោលបំណងដើម្បីបណ្តុះបញ្ញា សិល្បៈ និងជំនាញជាក់ស្តែងរបស់កុមារក្នុងលក្ខណៈរួម, កម្មវិធីសិក្សាត្រូវបានរៀបចំឡើងបន្សុីគ្នាទៅនឹងកម្រិតនៃការអភិវឌ្ឍន៍របស់កុមារ, រឿងនិទាន សិល្បៈ ការដេរប៉ាក់ ក្រង ចម្រៀង តម្រ្តី ចលនា ត្រូវបានបញ្ចូលក្នុងផ្នែកៗ នៃវិធីសាស្ត្រនេះ)
- **Bank Street Developmental-Interaction Approach** (ត្រូវបានចាក់ឫសដោយជំនឿថាកុមាររៀនបានល្អបំផុតនៅពេលដែលពួកគេចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្ររបស់ពួកគេ ហើយអាចទាក់ទងវាទៅនឹងបទពិសោធន៍របស់ពួកគេផ្ទាល់, បរិយាកាសក្នុងថ្នាក់រៀនត្រូវបានបង្កើតឡើងជាសហគមន៍តូចមួយ ដែលកុមារអាចស្វែងយល់ ពិសោធន៍ និងធ្វើអន្តរកម្ម។ ការសង្កត់ធ្ងន់គឺលើការអភិវឌ្ឍការគិតប្រកបដោយការរិះគន់ ជំនាញដោះស្រាយបញ្ហា និងការអភិវឌ្ឍន៍សង្គមរបស់កុមារ)



# វិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យសិក្សា

## វិធីសាស្ត្របង្រៀនជាទូទៅសម្រាប់មត្តេយ្យសិក្សា៖

- **High Scope Curriculum** (ការរៀនសូត្រដោយការចូលរួមយ៉ាងសកម្ម ដែលក្នុងនោះកុមារ និងមនុស្សធំរៀនជាមួយគ្នា, ទម្លាប់ប្រចាំថ្ងៃដើរតួនាទីយ៉ាងសំខាន់ ដោយសង្កត់ធ្ងន់ជាពិសេសលើលំដាប់ "ផែនការ-ធ្វើ-ពិនិត្យឡើងវិញ" , នេះធានាថាកុមារធ្វើការសម្រេចចិត្តអំពីអ្វីដែលពួកគេនឹងធ្វើ អនុវត្តគំនិតរបស់ពួកគេ ហើយបន្ទាប់មកឆ្លុះបញ្ចាំងពីសកម្មភាពរបស់ពួកគេ។ វិធីសាស្ត្រនៃការបង្រៀនសម្រាប់មត្តេយ្យសិក្សានេះជំរុញយ៉ាងខ្លាំងដល់ការរៀនដោយខ្លួនឯងដែលផ្តួចផ្តើមគំនិត)







# វិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យសិក្សា

**វិធីសាស្ត្ររួមបញ្ចូលគ្នា ឬវិធីសាស្ត្រចម្រុះសម្រាប់ការបង្រៀននិងរៀនមត្តេយ្យសិក្សា**

- **Play-based learning** ការរៀនតាមរយៈការលេង
- **Storytelling and puppetry** និទានរឿង ឬ អាយ៉ង
- **Field trips and real-world exploration** ដំណើរកំសាន្ត និងការរុករកពិភពពិត
- **Forest Schools** សាលាមត្តេយ្យព្រៃឈើ
- **Sensory Play** ការលេងដោយប្រើអារម្មណ៍ ឬញាណ
- **Thematic Units** បង្កើតប្រធានបទជាដំណាក់ៗ
- **Whole Brain Teaching** ការបង្រៀនដោយប្រើខួរក្បាលទាំងស្រុង
- **Differentiated Instruction** ការណែនាំបញ្ជ្រសទិស
- **Interactive technology tools** អន្តរកម្មតាមរយៈបច្ចេកវិទ្យា
- **Group activities and peer learning** សកម្មភាពជាក្រុម និងការរៀនពីមិត្តភក្តិ



# សន្និដ្ឋាន

ស្ថានភាពការរៀន និងបង្រៀននៅកម្រិតមត្តេយ្យសិក្សាបច្ចុប្បន្ន យោងតាមរបាយការណ៍នៃការ អនុវត្តកម្មវិធីសិក្សារបស់អ្នកគ្រូមួយចំនួនធំគឺ ការអនុវត្តដាច់ៗ ពីគ្នា តាមមុខវិជ្ជាក្នុងកម្មវិធីសិក្សា រួមមានមុខវិជ្ជា ចិត្តចលភាព ភាសាខ្មែរ បុរេគណិត វិទ្យាសាស្ត្រ និងសិក្សាសង្គម ដែលនាំឱ្យអ្នកគ្រូមានកិច្ចការច្រើនដូចជាសរសេរកិច្ចតែងការតាមមុខវិជ្ជានីមួយៗ និងមិនសូវមានពេលស្រាវជ្រាវវិធីសាស្ត្រថ្មីៗ ឬវិធីសាស្ត្រដែលអាចយក មកប្រើសម្រាប់បង្រៀនកុមារតូចបានរលូននិងល្អប្រសើរទេ។

ជាជម្រើស ប្រសិនបើអ្នកគ្រូអាចរួមគ្នាគិត និងស្រាវជ្រាវលើវិធីសាស្ត្រផ្សេងៗ ដូចជាវិធីសាស្ត្រចម្រុះ វិធីសាស្ត្ររៀនតាមរយៈបង្កើតប្រធានបទសិក្សាជាដំណាក់ៗ ខាងលើ នោះអ្នកគ្រូនឹងអាចកាត់បន្ថយរយៈពេលគ្រោងផែនការបង្រៀន គ្រោងកិច្ចតែងការបង្រៀន និងបង្រៀនចំទិសដៅ ដែលស្របតាមសមត្ថភាពកុមារ និងទេពកោសល្យរបស់កុមារដែលជួយពន្លឿនពួកគាត់បានទទួលការអភិវឌ្ឍន៍ពេញលេញដែលបណ្តុះជំនាញដែលសង្គមត្រូវការ គឺជំនាញនិងបំណិនក្នុងសតវត្សទី ២១ នេះតែម្តង។




សូមបន្តជូនអ្នកគ្រូ បង្ហាញអំពីការរៀនតាមរយៈការលេងនៅកម្រិតមត្តេយ្យសិក្សាដោយអ្នកគ្រូ អ៊ឹង ដាវីន គ្រូមត្តេយ្យសិក្សាសាលាមត្តេយ្យអនុវត្ត នៃសាលាគរុកោសល្យមត្តេយ្យមជ្ឈឹម សូមអរគុណ!